# សាលាអន្តរជាតិឡូហ្គោស
# ការណែនាំត្រួសៗសម្រាប់មាតាបិតាសិស្សថ្មី

សូមស្វាគមន៍មកកាន់សាលាឡូហ្គោស (ហៅកាត់ថា LIS)! យើងខ្ញុំមានសេចក្តីរសោមនស្សរីករាយណាស់ដែលលោកអ្នកបានចូលជាសមាជិកក្នុងសហាគមន៍មាតាបិតាសិស្សរបស់សាលាឡូហ្គោសយើងខ្ញុំ!
យើងខ្ញុំសូមជំរុញលើកទឹកចិត្តមាតាបិតាសិស្សទាំងអស់អោយអាននូវពត៌មានថ្មីៗក្នុងសៀវភៅបទពញ្ញាផ្ទៃក្នុងរបស់សាលាឡូហ្គោសទាំងអស់គ្នា  ប៉ុន្តែមុនឈានទៅដល់អានបទបញ្ញាផ្ទៃក្នុងទាំងមូល លោកអ្នកអាចចាប់ផ្តើមស្វែងយល់ពីពត៌មានត្រួសៗជាមុនសិន។
*****សាលាអន្តរជាតិឡូហ្គោសគឺជាស្ថាប័នអប់រំបែបគ្រឹះសាសនាដែលប្រើប្រាស់ព្រះគម្ពីរជាមូលដ្ឋាននៃកម្មវិធីសិក្សានឹងជាគ្រឹះនៃសហាគមន៍ឡូហ្គោស។ សូមលោកអ្នកជ្រាបថាសាលានឹងបង្រៀនអំពីទស្សនៈគ្រឹះសាសនាដល់កូនលោកអ្នក។

**សេចក្តីថ្លែងការណ៍ពីបេសកម្ម Mission Statement**
សាលាអន្តរជាតិឡូហ្គោសមានការប្តេជ្ញាចិត្តក្នុងការរៀបចំកម្មវិធីសិក្សាមួយដែលមានកំរិតស្តង់ដាខ្ពស់ ក្នុងការផ្តល់នូវគុណភាពអប់រំគ្រប់ជ្រុងជ្រោយ និង ការអប់រំតាមបែប គ្រីស្តសាសនាទៅកាន់សិស្ស គ្រប់រូបដែលមកពីគ្រប់ស្រទាប់វណ្ណៈ ។ ក្រោយពីបញ្ចប់ឆ្នាំសិក្សា សិស្សគ្រប់រូបនឹងទទួលបាន ការបណ្តុះបណ្តាលឲ្យចេះពិនិត្យពិចារណាលើ គ្រប់បែនផែននៃជីវិតចេញពីទស្សនៈព្រះគម្ពីរដើម្បីបម្រើ និង ជួយបម្លាស់ប្រែសហាគមន៍ របស់ពួកគេសំរាប់ព្រះគ្រីស្ត និងដើម្បីបន្តការអប់រំឲ្យបានជ្រៅជ្រះនៅកំរិតឧត្តមសិក្សា ។
**សេចក្តីថ្លែងការណ៍ពីចក្ខុវិស័យ Vision Statement**
សិស្សគ្រប់រូបនឹងទទួលបានការបង្ហាត់បង្រៀនឲ្យក្លាយទៅជាបុគ្គលម្នាក់ដែលមានភាពចាស់ទុំផ្នែក ព្រលឹងវិញ្ញាណ  ដែលមានចំណេះដឹងខ្ពង់ខ្ពស់ និង បុគ្គលម្នាក់ដែលមានទំនួលខុសត្រូវក្នុងសង្គម។
**ពាក្យស្លោក: បេះដូវព្រះគ្រីស សម្រាប់សេចក្តីពិតដល់ពិភពលោកទាំងមូល។**

__**សូមប្រាកដថាការិយាល័យសិក្សារបស់សាលាមានអ៊ីម៉ែលរបស់លោកអ្នកសម្រាប់ពត៌មានប្រចាំសប្តាហ៍។__
ពត៌មានប្រចាំសប្តាហ៍គឺជាពត៌មានដែលផ្ញើរចេញតាមរយៈអ៊ីម៉ែលដែលនិយាយអំពីកម្មវិធីផ្សេងៗ ការប្រកាសដំណឹងពី ប្រធានសាលា ។ល។ ការទទួលនូវអ៊ីម៉ែលពត៌មានប្រចាំសប្តាហ៍នេះនឹងជួយដល់លោកអ្នកដឹងពីពត៌មានថ្មីៗដែលទាក់ទងនិង សាលាឡូហ្គោស។
__**ក្នុងនាមជាមាតាបិតា លោកអ្នកនិងត្រូវបានចូលជាចំណែកនៃសហាគមន៍មាតាបិតាសិស្សដោយស្វ័យប្រវត្តិ (ដែលហៅកាត់ថា LPA)។__ គោលដៅរប់សសហាគមន៍មានតាបិតាសិស្ស គឺជួយដល់ប្រធានសាលា លោកគ្រូអ្នកគ្រូ និងដល់សិស្សានុសិស្សទាំងអស់។ សូមមើលពត៌មានប្រចាំសប្តាហ៍ដើម្បីដឹងពីថ្ងៃប្រជុំ ពេលវេលា និងរបៀបក្នុងការស្មគ្រ័ចិត្តជួយដល់សាលា។
__**ការបង់ប្រាក់សម្រាប់ថ្លៃសាលាត្រូវបង់ជារៀងរាល់ដើមខែថ្ងៃទី១។__ ជារៀងរាល់ខែរាល់ការបង់ប្រាក់ក្រោយថ្ងៃទី១០ និងមានការផាកពិន័យ ១០ភាគរយបន្ថែម។ (សូមមើលសៀវភៅបទញ្ញាផ្ទៃក្នុងសាលាឡូហ្គោសពីពត៌មានលំអិត)។

__**ភាសាអង់គ្លេសជាភាសាដែលនិងត្រូវបានប្រើប្រាស់ក្នុងបរិវេណសាលាឡូហ្គោស។__
ភាសាអង់គ្លេសនិងប្រើសម្រាប់ការបង្ហាត់បង្ហាញទាំងអស់។ ហើយសិស្សានុសិស្សាទាំងអស់ត្រូវតែប្រើប្រាស់ជាភាសាអង់គ្លេសគ្រប់ពេលក្នុងកំឡុងម៉ោងសិក្សាពេញមួយថ្ងៃ។

__**ក្នុងនាមជាសាលាគ្រីស្ទាន សាលាឡូហ្គោសតែងតែមានកម្មវិធីការប្រជុំថ្វាយបង្គំសម្រាប់សិស្សគ្រប់កម្រិតថ្នាក់។__
គ្រប់សិស្សានុសិស្សាទាំងអស់តម្រូវត្រូវអោយចូលរួមក្នុងកម្មវិធីនេះ។

__**សិស្សចាប់ពីថ្នាក់មតេយ្យអាយុ៥ឆ្នាំដល់ថ្នាក់ទី១២សាលាតម្រូវត្រូវអោយពាក់ឯកសណ្ឋាន។__
**ឯកសណ្ឋានកីឡាតម្រូវអោយថ្នាក់មតេយ្យ៣ឆ្នាំនិង៤ឆ្នាំទាំងអស់ពាក់ក្នុងពេលមានម៉ោងកីឡា/ហាត់ប្រាណ។**
ឯកសណ្ឋានសាលាអាចទិញបាននៅក្នុងមួយសប្តាហ៍ដំបូងមុនពេលចូលរៀន។ការិយាល័យសាលាក៏មានឯកសណ្ឋានស្តុកសម្រាប់លក់ក្នុងកំឡុងឆ្នាំសិក្សាដែរ។ (សូមមើលសៀវភៅបទញ្ញាផ្ទៃក្នុងសាលាឡូហ្គោសពីពត៌មានលំអិត)។
**<u>មតេយ្យថ្នាក់អាយុ៣ឆ្នាំ និង៤ឆ្នាំ</u>**
**សិស្សទាំងអស់៖** ឯកសណ្ឋានកីឡា តម្រូវអោយពាក់ពេលមានថ្នាក់ហែលទឹក និងថ្នាក់កីឡា។
**សិស្សបឋមសិក្សាកម្រិតមតេយ្យ៥ឆ្នាំ ដល់ថ្នាក់ទី៥៖**

**<u>សិស្សប្រុស</u>៖** ឯកសណ្ឋានអាវពណ៌ផ្ទៃមេឃ ខោជើងខ្លី វែងពណ៌កាគី ឬទឹកប៊ិច
(ហាមមិនអោយមានហោប៉ៅនៅខាងក្រៅទេ)។

**<u>សិស្សស្រី</u>៖** ឯកសណ្ឋានអាវពណ៌ផ្ទៃមេឃ ខោជើងខ្លី វែង សំពត់ពណ៌កាគី ឬទឹកប៊ិច

(ហាមមិនអោយមានហោបៅនៅខាងក្រៅទេ)។

**<u>សិស្សអនុវិទ្យាល័យ (ថ្នាក់ទី ៦ ដល់ទី ៨)</u>**

**<u>សិស្សប្រុស៖</u>** ឯកសណ្ឋានអាវពណ៌ស ឬក្រហមក្រម៉ៅ ខោជើងខ្លី វែងពណ៌កាគី ពណ៌ខ្មៅ ឬទឹកប៊ិច (ហាមមិនអោយមានហោបៅនៅខាងក្រៅទេ)។

**<u>សិស្សស្រី៖</u>** ឯកសណ្ឋានអាវពណ៌ស ឬក្រហមក្រម៉ៅ ខោជើងខ្លី វែង សំពត់ពណ៌កាគី ពណ៌ខ្មៅ ឬទឹកប៊ិច (ហាមមិនអោយមានហោបៅនៅខាងក្រៅទេ)។

**<u>សិស្សវិទ្យាល័យ (ថ្នាក់ទី៩ ដល់ទី១២)</u>**

**<u>សិស្សប្រុស៖</u>** ឯកសណ្ឋានអាវពណ៌ស ឬពណ៌ទឹកប៊ិច ខោជើងខ្លី វែងពណ៌កាគី ពណ៌ខ្មៅ ឬទឹកប៊ិច (ហាមមិនអោយមានហោបៅនៅខាងក្រៅទេ)។

**<u>សិស្សស្រី៖</u>** ឯកសណ្ឋានអាវពណ៌ស ឬពណ៌ទឹកប៊ិច ខោជើងខ្លី វែង សំពត់ពណ៌កាគី ពណ៌ខ្មៅ ឬទឹកប៊ិច (ហាមមិនអោយមានហោបៅនៅខាងក្រៅទេ)។

**ផ្នែកកីឡា ( ចាប់ពីថ្នាក់មតេយ្យ ដល់ ថ្នាក់ទី ១២ សិស្សប្រុស និង សិស្សស្រី )**
ឯកសណ្ឋានកីឡាជាផ្លូវការណ៍បន្ថែមក៏តម្រូវឲ្យសិស្សទិញផងដែរដើម្បីពាក់ក្នុងពេលម៉ោងកីឡា។

**** សិស្សអាចយកអាហារថ្ងៃត្រង់ផ្ទាល់ខ្លួនមកសាលា ឬ សិស្សអាចទិញ អាហារថ្ងៃត្រង់ ក្នុងអាហារដ្ឋានសាលាបានដោយមានការបង់ថ្លៃបន្ថែម ។** (សំរាប់ព័ត៌មានលំអិត សូមទាក់ទងការិយាល័យសាលា)

**** សុខភាព និង ថ្នាំពេទ្យ:** សាលាឡូហ្គោសមានគិលានុបដ្ឋាយិកាបម្រើការងារ ពេញម៉ោងប្រចាំក្នុងសាលា ។ សូមធ្វើការទំនាក់ទំនងជាមួយគិលានុបដ្ឋាយិកា ប្រសិនបើកូនៗរបស់លោកអ្នកតម្រូវឲ្យទទួលទានថ្នាំទៀងទាត់ពេលក្នុងកំឡុងពេលរៀនក្នុងសាលា ។ សាលានឹងគោរពតាមច្បាប់ ២៤ ម៉ោងសំរាប់ ការក្ដៅខ្លួន ការក្អួត និង រោគសញ្ញាផ្សេងៗទៀតដែលអាចចម្លងទៅសិស្សផ្សេងបាន ។
( សំរាប់ព័ត៌មានលំអិត សូមមើលក្នុងសៀវភៅបទបញ្ជាផ្ទៃក្នុងរបស់សាលា )

***** ការទំនាក់ទំនងផ្នែកមធ្យមសិក្សា:*** Rosariosis គឺជាប្រព័ន្ធព័ត៌មានសិស្សដែលកត់ត្រាវត្តមាន និង ពិន្ទុសិស្ស។ មាតាបិតាសិស្សត្រូវបាន លើកទឹកចិត្តឲ្យបង្កើតគណនីមួយដែលអាចចូលទៅពិនិត្យមើលពិន្ទុរបស់កូនលោកអ្នកតាមប្រព័ន្ធ ព័ត៌មាន **Rosariosis** ។ ដើម្បីបង្កើតគណនីនោះ លោកអ្នកអាចធ្វើការទំនាក់ទំនងនៅ ការិយាល័យ ឬ ផ្ញើអ៊ីមែលទៅកញ្ញា សុជាតា តាម : office@logoscambodia.org.

**** យកគ្រឿងអេឡិចត្រូនិចផ្ទាល់ខ្លួន (BYOD) : ថ្នាក់ទី១១ - ១២ : តម្រូវអោយមានកុំព្យូទ័រ (Laptop) ផ្ទាល់ខ្លួន និងថ្នាក់ទី ៩ - ១០ : ត្រូវមានគ្រឿងអេឡិចត្រូនិចដែលអាចប្រើជាមួយប្រព័ន្ធអ៊ីធឺណែតបាន (តែបើជាTablet នោះល្អ) ។**

** ***សិស្សអនុវិទ្យាល័យ និង វិទ្យាល័យនឹងតម្រូវឲ្យមាន locker នៅរៀងរាល់ដើមឆ្នាំសិក្សានីមួយៗ ។***
សិស្សគ្រប់រូបនឹងតម្រូវឲ្យប្រគល់លេខសោសម្ងាត់ផ្ទាល់ខ្លួនមកសាលា (សំរាប់ព័ត៌មានលំអិត សូមមើលក្នុងសៀវភៅបទបញ្ជាផ្ទៃក្នុងរបស់សាលា )

** *សកម្មភាពនៃកម្មវិធីសិក្សាបន្ថែម និង កម្មវិធីកីឡាមានសំរាប់ថ្នាក់ទី ៦ ដល់ ទី ១២ ។* កម្មវិធីសិក្សាបន្ថែមនេះក៏អាចត្រូវឲ្យបង់លុយផងដែរ ។ ( សំរាប់ព័ត៌មានលំអិត សូមមើលក្នុងសៀវភៅបទបញ្ជាផ្ទៃក្នុងរបស់សាលា )

** សំណួរអំពីការដាក់ពិន្ទុ កិច្ចការផ្ទះ បែបបទបញ្ចប់ការសិក្សា វិធានការណ៍វិន័យរបស់សាលា ការរំពឹងទុកពីអាកប្បកិរិយារបស់សិស្ស ទំនួលខុសត្រូវ និងសិទ្ធិរបស់សិស្ស ភ្ញៀវដែលចូលក្នុងបរិវេណសាលា ច្បាប់ពីការប្រើប្រាស់គ្រឿងអេឡិចត្រូនិចរបស់សិស្ស ។ល។ ( សំរាប់ព័ត៌មានលំអិត សូមមើលក្នុងសៀវភៅបទបញ្ជាផ្ទៃក្នុងរបស់សាលា )។

** សំរាប់សៀវភៅបទបញ្ជាផ្ទៃក្នុងរបស់ឪពុកម្ដាយ និង សិស្ស លោកអ្នកអាចចូលទៅកាន់គេហទំព័រ : www.logoscambodia.org**

**លោកអ្នកអាចធ្វើការទំនាក់ទំនងមកសាលាតាមរយ: ៖**

ការិយាល័យសាលាឡូហ្គោស : 017- 473 - 515 អ៊ីមែល : office@logoscambodia.org
លោក Mike Belloni នាយកសាលាផ្នែកបឋមសិក្សា : mbelloni@asianhope.org
លោកស្រី Joy Young នាយកសាលាផ្នែកមធ្យមសិក្សា : jyoung@asianhope.org
លោក Philip Workman ប្រធានចាត់ចែកប្រតិបត្តិការសាលា: pworkman@asianhope.org
លោកស្រី Pam Sephton ប្រធានគ្រប់គ្រងផ្នែកអប់រំ : psephton@asianhope.org
លោកស្រី Jen Sain ប្រធានសមាគម ឪពុកម្ដាយ និង សាលាឡូហ្គោស : lpa@logoscambodia.org